# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH WATER SUPPLY AUTHORITY
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ ០៦១...ស.ជ.ណ

ថ្ងៃព្រហ...១៤រោច...ខែ...ពិសាខ...ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី...២១...ខែឧសភា...ឆ្នាំ២០២០

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្រាប់ឆ្នាំ២០២០។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី១១ខែសីហា ឆ្នាំ២០២០ ត្រឹមវេលាម៉ោង ១៦:០០ល្ងាច ក្នុងមួយច្បាប់តម្លៃ ៥០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៤:០០នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) អាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ ក្នុងឯកសារដេញថ្លៃ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**អគ្គនាយក**

**ស៊ឹម ស៊ីថា**

ចម្លងជូន៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh